# ឧក្រិដ្ឋកម្មនៃការគោរពតាមបទបញ្ជា

**សាស្ត្រាចារ្យ ដេវីដ សេហ្វឺ**

**ថ្ងៃទី២៦ វិច្ឆិកា ឆ្នាំ២០០៩**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

កាលពីថ្ងៃព្រហស្បតិ៍ ទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ហ្វ្រង់ស័រ រូ មេធាវីការពារក្តីអន្តរជាតិបានក្រោកឈរថ្លែងពីការបញ្ចប់ការសួរដេញដោលដែលមានរយៈពេលប្រមាណ ៤ម៉ោង ក្នុងតុលាការកាត់ទោសកាំង ហ្គេចអ៊ាវ (ហៅ ឌុច) នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ ជាកិច្ចចាប់ផ្តើម ហ្វ្រង់ស័រ រូ បានធ្វើសេចក្តីប្រកាសពីរប្រឈមប្រឡល់គ្នា ៖ ទីមួយ លោកនឹងធ្វើការពិនិត្យសារឡើងវិញពីអំណះអំណាងរបស់លោក ដែលទាក់ទិននឹងសេចក្តីអះអាងធ្វើឡើងដោយសហមេធាវីការពារក្តីជាតិរបស់លោកគឺ ការ សាវុត្ថ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។ ទីពីរ លោកបាននិយាយថា នេះគឺជាអំណះអំណាងចុងក្រោយរបស់លោកក្នុងនាមជាមេធាវី ។ ដោយបង្ហាញការគោរពជាលើកចុងក្រោយ ហ្វ្រង់ស័រ រូ បាននិយាយថា វាមានរយៈពេល៣៧ឆ្នាំហើយចាប់តាំងពីលោកធ្វើពាក្យសម្បថធ្វើជាមេធាវី ហើយនៅថ្ងៃចុងបញ្ចប់នេះ លោកនឹងដោះអាវមេធាវីរបស់លោកចេញ ។ លោកនឹងឆ្ពោះទៅកាន់ការិយាល័យសហមេធាវីរបស់តុលាការពិសេសនៃប្រទេសឡេបាណន់ក្នុងទីក្រុងហេក និងអនុវត្តសេចក្តីខិតខំប្រឹងប្រែងបន្តរបស់លោកក្នុងកាតព្វកិច្ចបំពេញយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ ។ លោកធ្វើការផ្តាំផ្ញើរក្នុងអំឡុងថ្ងៃនេះ ទៅកាន់កូនចៅរបស់លោក និងយុវជនជំនាន់ក្រោយជាពិសេស គឺទៅកាន់មេធាវីនារីវ័យក្មេងនៅក្នុងក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងបន្ទប់អង្គសវនាការ ។

ហ្វ្រង់ស័រ រូ បាននិយាយបន្តទៀតថា “ការក្រោកឈរនិយាយការពារក្តី គឺជាកិច្ចការងារ ដែលធ្វើឲ្យការងាររបស់យើងប្រកបដោយភាពកោតសរសើរ” ។ លោកបានគាំទ្រ“ជនត្រូវចោទម្នាក់ក្នុងចំណោមជនត្រូវចោទពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដែលមិនអាចនឹកស្មានដល់ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ នៅពេលដែលខ្ញុំបានឮរឿងមិនពិតដ៏ច្រើនសន្ធឹកសន្ធាប់ដែលរៀបរាប់ដោយសហព្រះរាជអាជ្ញា ប៉ុន្តែមិនបានឮពីរឿងរ៉ាវទាក់ទិននឹងមនុស្សជាតិ ដែលជនត្រូវចោទបានរៀបរាប់ដល់សហព្រះរាជអាជ្ញាជាមួយនឹងការចោទប្រកាន់យ៉ាងច្រើនមកលើជនត្រូវចោទទៅវិញ ខ្ញុំក៏ក្រោកឈរការពារក្តីក្នុងនាមជាមេធាវី

ការពារកូនក្តីរបស់ខ្ញុំ ។ លោកបាននិយាយថា «នៅក្រោមអាវជាមេធាវីការពារក្តី មានមនុស្សម្នាក់ដែលមានទុក្ខកង្វល់យ៉ាងខ្លាំងចំពោះអ្វីដែលជនរងគ្រោះបានឆ្លងកាត់ ។ សេចក្តីស្រឡាញ់ និងគោរពរបស់ខ្ញុំក្នុងនាមជាមនុស្សម្នាក់បានប្រាប់ខ្ញុំនៅព្រឹកនេះថា ខ្ញុំពិតជាមានភាពរីករាយក្នុងការស្តាប់គ្រប់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់និយាយថា តុលាការសម្រាប់កូនក្តីរបស់យើងមួយនេះ គឺជាជំហានដំបូងមួយដែលឆ្ពោះទៅរកការបំបាត់នូវភាពទុក្ខសោក ។ សូមយើងទាំងអស់គ្នាអបអរសាទរជាមួយនឹងតំណក់ទឹកដ៏តិចតួចនេះ ដែលថាវានឹងជួយរំសាយរាល់ទុក្ខលំបាកវេទនា ដែលជនរងគ្រោះទាំងអស់បានទទួលរង ។ នេះគឺជាចំណាប់ផ្តើមដំបូង ក្នុងការធ្វើឲ្យមានភាពប្រាកដប្រជាថា រឿងនេះបានកើតឡើងជាលើកដំបូងនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ចំពោះវត្តមានជនរងគ្រោះដែលបានធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី» ។

បើមើលទៅកាន់អង្គជំនុំជម្រះខ្លួនឯងផ្ទាល់វិញ ហ្វ្រង់ស្វ័រ រូ បានសួរថា «តើមានជនអគតិចំនួនប៉ុន្មាននាក់ដែលគិតថា តុលាការនេះនឹងគ្មានថ្ងៃកើតឡើងនោះ»? ប៉ុន្តែតុលាការកាត់ទោសបានស្ថាបនាឡើងដោយមានបញ្ហាស្មុគស្មាញជាច្រើនដែលយើងត្រូវតែដោះស្រាយនិងពុះពារ ។ ជាក់ស្តែង យើងបានមកដល់ចំណុចចុងក្រោយនេះហើយ យើងបានសម្រេចកិច្ចការនេះរួចជាស្ថាពរ ។ ថ្ងៃនេះយើង អាចនិយាយបានថា តុលាការកាត់ទោសនេះនឹងត្រូវបានចារទុកក្នុងទំព័រប្រវត្តិសាស្រ្តស្តីពីយុត្តិធម៌ ឧក្រិដ្ឋកម្មអន្តរជាតិដែលកំពុងតែធ្វើដំណើរវិវត្តន៍នៅក្នុងសម័យកាលរបស់យើងគ្រប់គ្នា ។ ប៉ុន្តែ វានៅមានភាពក្មេងខ្ចីនៅឡើយ ដូច្នេះយើងទាំងអស់គ្នាកំពុងព្យាយាមស្វែងរកមធ្យោបាយល្អបំផុត ដើម្បីដើរឆ្ពោះទៅមុខ ។ នៅទីបញ្ចប់ យុត្តិធម៌នឹងត្រូវបានផ្តល់ឲ្យ ។ យ៉ាងណាមិញ សម្រាប់ចៅក្រម អ្នកមិនមែនជាបុគ្គលដែលទទួលបន្ទុកក្នុងការស្វែងរកការផ្សះផ្សានោះទេ ។ អ្នកមិនអាចបង្ខំឲ្យមានការផ្សះផ្សាឡើយ ប៉ុន្តែអ្នកត្រូវតែផ្តល់នូវយុត្តិធម៌ ។ លោកចៅក្រមទាំងអស់មានវត្តមាននៅទីនេះ គឺដើម្បីធ្វើការប្រឆាំងនឹងវប្បធម៌នៃនិទណ្ឌភាព ដែលនេះគឺជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ។ អ្នកមានវត្តមាននៅទីនេះ គឺដើម្បីផ្តល់យុត្តិធម៌ នៅក្នុងតុលាការដែលកិច្ចខិតខំប្រឹងប្រែងរបស់តុលាការនេះ គឺធ្វើឲ្យមានដំណើរការនីតិវិធីដែលមានអ្នកភាគីចូលរួមច្រើន ។

ក្រោយពីបានកត់សម្គាល់ពីកិច្ចការគណៈកម្មាការស្វែងរកការពិត និងការផ្សះផ្សា រួមជាមួយនឹងការនិពន្ធរបស់ ដេសមិន ទូទូ ដែលបានធ្វើឲ្យពូជសាសន៍របស់មនុស្សបានកកើតសារជាថ្មីម្តងទៀត នៅក្នុងប្រទេសរបស់គាត់ ហ្វ្រង់ស្វ័រ រូ បាននិយាយថា «ភាគច្រើន យើងបានបញ្ចេញនូវចំណាប់អារម្មណ៍

មួយដែលថាយើងទាំងអស់គ្នាហាក់បីដូចជាបានកំពុងតែចូលរួមនៅក្នុងគណៈកម្មាការស្វែងរកការពិត និង ការផ្សះផ្សានៅក្នុងបន្ទប់សវនាការនេះ ។ វាគឺជាកិត្តិយសមួយសម្រាប់ប្រទេសកម្ពុជា ដែលតុលាការ នេះ បានអនុញ្ញាតឲ្យមនុស្សជាច្រើនបានតាមដានដំណើរការកាត់ទោសដែលបានបំរើជានិម្មិតរូបមួយ សម្រាប់គោលដៅកាត់ទោសនេះ» ។

## ការខ្វែងគំនិតគ្នារវាងសហមេធាវីការពារក្តី

ហ្វ្រង់ស៊័រ រូ បានទទួលស្គាល់ចំពោះអ្វីដែលបានកើតឡើងច្បាស់ណាស់កាលពីថ្ងៃពុធ ៖ ការខ្វែងគំនិតគ្នា នាពេលចុងក្រោយរវាងយុត្តិសាស្ត្ររបស់លោកសម្រាប់ការការពារក្តីឲ្យ ឌុច និងយុត្តិសាស្ត្ររបស់ សហមេធាវីការពារក្តីជាតិ ការ សាវុត្ថ ។ ហ្វ្រង់ស៊័រ រូ បានចាត់ទុកចំណុចខ្លះនៃគោលដៅការពារក្តី របស់ ការ សាវុត្ថ ថាមិនអាចទទួលយកបាននិងឲ្យ ការ សាវុត្ថ រៀបចំសេចក្តីជំទាស់ដោយខ្លួនឯង សម្រាប់សេចក្តីជំទាស់ដែលប្រាកដនឹងធ្វើឡើងដោយសហព្រះរាជអាជ្ញា ។ ដំបូងនិងសំខាន់ជាងគេនេះគឺ ហ្វ្រង់ស៊័រ រូ បានទទួលស្គាល់ថា ច្បាប់ករណីរបស់តុលាការឧក្រិដ្ឋកម្មសម្រាប់អតីតយូហ្គោស្លាវី បាន ធ្វើការដោះស្រាយបញ្ហាជាច្រើន ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យសម្រាប់ជនដែលចាត់ទុកថា នៅក្នុង ក្រុមមនុស្សដែល«មានទំនួលខុសត្រូវខ្ពស់បំផុត»សម្រាប់គណៈកម្មាការអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋ កម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ច្បាប់ជាតិរបស់កម្ពុជា គឺជាធម្មតាមិនមានជាប់ ពាក់ព័ន្ធនឹងបញ្ហានោះទេ «ដូច្នេះច្បាប់អន្តរជាតិត្រូវតែទទួលបានលទ្ធផល» ។ ច្បាប់អន្តរជាតិត្រូវបាន ដាក់បញ្ចូលទៅក្នុងច្បាប់ជាតិនៅក្នុងករណីនេះ ។

ទីពីរ ហ្វ្រង់ស៊័រ រូ ត្រូវតែបង្ហាញពីការពិតដ៏ស្មុគស្មាញដែលថា ការ សាវុត្ថ បានអះអាងពីភាពគ្មាន ទោសរបស់ ឌុច តាមច្បាប់របស់ អ.វ.ត.ក និងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងស្នើសុំឲ្យមានសាល ក្រមសម្រេចឲ្យរួចទោសពីបទចោទប្រកាន់ទាំងឡាយនោះ ។ ផ្ទុយទៅវិញ អស់រយៈពេលជាច្រើនខែ ដែល ហ្វ្រង់ស៊័រ រូ បានណែនាំកូនក្តីរបស់គាត់តាមរយៈការបង្ហាញពីទំនួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ក្នុងឥរិយាបថដែលបានចាត់ទុកថា ជាការយល់ព្រមទទួលពិរុទ្ធភាពតាមបែប យល់ឃើញតែប៉ុណ្ណោះ (បើទោះបីជាការយល់ព្រមបែបនេះ មិនមាននៅក្នុងច្បាប់របស់ អ.វ.ត.ក ក៏ដោយ) ។ លោកបានបន្តទៀតថា «យើងមិនអាចសំណូមពរឲ្យមានសាលក្រមសម្រេចរួចទោសពី បទចោទប្រកាន់សម្រាប់ជនត្រូវចោទនោះទេ និងរួមទាំងការយល់ព្រមទទួលពិរុទ្ធភាពជំនួសឲ្យ ឌុច

ផងដែរ» ។ បើទោះបីជា ឌុច មិនយល់ព្រមទទួលពិរុទ្ធភាពក៏ដោយ តើនរណាទៀតនៅមានគោលជំហរតវ៉ាជាមួយទឹកភ្នែកដែល ឌុច បានជូតនោះ? តើនរណាអាចបដិសេធចំពោះការសុំទោសរបស់ ឌុច បាន? ទាំងនេះ គឺជាការពិតដែលត្រូវបានឆ្លងកាត់ដោយជនត្រូវចោទ ហើយខ្លួនបានជូតទឹកភ្នែកនៅចំពោះមុខជនរងគ្រោះ និងសហព្រះរាជអាជ្ញា និងអ្នកដែលអះអាងថា «ទាំងនេះគឺជាពាក្យសម្ដីដែលខ្ញុំបានរង់ចាំអស់រយៈពេលជាង៣០ឆ្នាំមកហើយ ។ តើមាននរណាអាចបដិសេធបានដែរឬទេ? ឌុច បានសម្ដែងការសុំទោសតាមរយៈពាក្យសម្ដីទាំងអស់នេះដោយភាពស្មោះត្រង់ជាទីបំផុត ព្រមទាំងមានភាពរំជើបរំជួលដោយពាក្យសម្ដីខ្លួនឯងផ្ទាល់ផងដែរ» ។

ហ្វ្រង់ស៊័រ រូ បានមានប្រសាសន៍ថា ឌុច បានទទួលស្គាល់កំហុសរបស់ខ្លួន ដូច្នេះហេតុការណ៍មួយនេះត្រូវបានចាត់ទុកថា ជាទេសកាលប្រវត្តិសាស្ត្រមួយសម្រាប់ប្រទេសកម្ពុជា ។ លោកបានផ្តល់ដំបូន្មានថា «យើងទាំងអស់គ្នាត្រូវតែស្វែងរកការពិត» ។ «យើងបានស្តាប់ឮបុរសម្នាក់លុតជង្គង់សុំទោសកាលពីម្សិលមិញ» ។

## អ្វីដែលបានកើតឡើងពីមុនសម្រាប់ករណីកាត់ទោស Dragan អុប្រើណូវិច

បន្តិចក្រោយមក ហ្វ្រង់ស៊័រ រូ បានទទួលការអនុញ្ញាតពីចៅក្រមឲ្យចាក់បញ្ចាំងវីដេអូដែលដកស្រង់ចេញពីតុលាការកាត់ទោសរបស់ Dragan អុប្រើណូវិច នៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ អុប្រើណូវិច គឺជាមេបញ្ជាការស្តីទីរបស់កងកម្លាំងប្រដាប់អាវុធ Zvornik Brigade របស់ប្រទេសប៊ូស្នៀន ដែលបានវាយកម្លាំងនៅក្នុងប្រទេសស្រ៊ីប្រេនីកា កាលពីខែកក្កដា ឆ្នាំ១៩៩៥ និងបានសម្លាប់បុរស និងក្មេងប្រុសគោរពសាសនាម៉ូស្លីមជាច្រើននាក់ ។ បានចូលរួមក្នុងកិច្ចព្រមព្រៀងទទួលស្គាល់ ជាមួយនឹងសហព្រះរាជអជ្ញារបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងយល់ព្រមទទួលស្គាល់ពិរុទ្ធភាពដែលត្រូវបានវិភាគឃើញថា ជាការកាត់ទោសសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល១៧ឆ្នាំ កាលពីថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០០៣ ។ វីដេអូដកស្រង់បានបង្ហាញពីការបញ្ចប់ការសួរដេញដោលរបស់ព្រះរាជអាជ្ញាទាក់ទិននឹងការកាត់ទោសរបស់ អុប្រើណូវិច ។ សេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់ព្រះរាជអាជ្ញា គឺជាសេចក្តីថ្លែងការណ៍ដែលរៀបរាប់បានយ៉ាងល្អ និងមានឥទ្ធិពលបញ្ចុះបញ្ចូលអ្នកតាមដាននៅក្នុងតុលាការកាត់ទោសរបស់ អ.វ.ត.ក បានទស្សនា ពីព្រោះថា ព្រះរាជអាជ្ញារបស់

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានពន្យល់រៀបរាប់ពីការទទួលស្គាល់ពិរុទ្ធភាព ការសម្តែងវិប្បដិសារី និងសហការរបស់ជនត្រូវចោទជាមួយនឹងព្រះរាជអាជ្ញា រួមជាមួយនឹងការផ្តល់នូវការពិតអំពីរឿងរ៉ាវដែលបានកើតមានឡើងនៅក្នុងប្រទេសស្រ៊ីប្រេនីកា និងមូលដ្ឋានចម្បងរបស់ព្រះរាជអាជ្ញា ក្នុងការសុំឲ្យមានការកាត់ទោសជាប់ពន្ធធានាគារតែត្រឹមរយៈពេល ១៧ឆ្នាំ ។

បន្ទាប់ពីការចាក់បញ្ចាំងវីឌីអូមក ហ្វ្រង់ស៊័រ រូ បានក្រោកឈរ និងនិយាយដោយធម្មតាថា «អ្នកទាំងអស់គ្នាបានឃើញពីការកាត់ទោសរបស់ អុប្រ៊ើណូវិច ហើយ ។ នេះគឺជាអ្វីដែលតុលាការកាត់ទោសនេះគួរតែធ្វើតាម ។ ចំនុចត្រង់នេះ អាចជួយរារាំងចំពោះអ្វីដែលបានកើតឡើង កាលពីពេលរសៀលម្សិលមិញនេះ (ការស្នើសុំការមានសាលក្រមសម្រេចឲ្យរួចទោសពីបទចោទប្រកាន់របស់ ការសារុត្ត) ។ ហ្វ្រង់ស៊័រ រូ បានសង្កត់ធ្ងន់ថា អុប្រ៊ើណូវិច មិនបានទទួលស្គាល់អ្វីៗគ្រប់យ៉ាងនោះទេ តាមពិតទៅលោកមិនបានយល់ព្រមទទួលស្គាល់ពិរុទ្ធភាពសម្រាប់បទចោទប្រកាន់ទាំងអស់ទេ រហូតមកដល់ថ្ងៃដំបូងរបស់តុលាការកាត់ទោសរបស់លោក ។ ក្រោយមក លោកបានទៅជួបជាមួយនឹងព្រះរាជអាជ្ញា ហើយទើបតែពេលនោះហើយដែល អុប្រ៊ើណូវិច យល់ព្រមទទួលស្គាល់ពិរុទ្ធភាពសម្រាប់បទចោទប្រកាន់មួយ ។ ហ្វ្រង់ស៊័រ រូ បាននិយាយថា «វាមិនមែនជាដំណោះស្រាយនោះទេ» ។ «វាគឺជាកិច្ចចរចាមួយ ការពិភាក្សាយោបល់មួយរវាងព្រះរាជអាជ្ញា និងជនត្រូវចោទតែប៉ុណ្ណោះ» ។

## សហព្រះរាជអាជ្ញាបាត់បង់ឱកាសក្នុងការធ្វើឲ្យការបញ្ចប់ការសួរដេញដោលនេះមានលក្ខណៈសំខាន់

ហ្វ្រង់ស៊័រ រូ បានបន្តទៀតថា នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូវ៍ (Civil Law) ការយល់ព្រមទទួលស្គាល់ពិរុទ្ធភាពមិនកើតមានឡើងដូចករណីនេះទេ ។ ប៉ុន្តែ ចៅក្រមអាចធ្វើការពិចារណាលើច្បាប់អន្តរជាតិសម្រាប់ភាពជាប់ពាក់ព័ន្ធគ្នាចំពោះអ្វីដែលចាត់ទុកថា ជាការយល់ព្រមទទួលស្គាល់ពិរុទ្ធភាពនៅក្នុងរឿងក្តី និងតុលាការកាត់ទោសរបស់បុគ្គលម្នាក់នេះ ។ «សហព្រះរាជអាជ្ញា បានបាត់បង់ឱកាសក្នុងការធ្វើឲ្យការបញ្ចប់ការសួរដេញដោលនេះមានលក្ខណៈសំខាន់ ហើយនេះបានបង្កឲ្យមានភាពអាក់អន់ចិត្តចំពោះទស្សនៈសាធារណៈក្នុងចំណោមជនរងគ្រោះដែលមូលហេតុថា ឌុច មិនបានប្រាប់អ្នកទាំងអស់នោះ ពីរឿងរ៉ាវទាំងអស់ដែល ឌុច គួរតែប្រាប់នោះ ។ នេះគឺជារឿងដែលមិនអាចទទួលយកបានទេ! តាំងពីដំបូងមក ឌុច បានប្រាប់សហចៅក្រមស៊ើបអង្កេតថា ឌុច មានពិរុទ្ធភាព និងយល់ព្រមទទួលខុសត្រូវរាល់ឧក្រិដ្ឋកម្មទាំងអស់ ។ សហព្រះរាជអាជ្ញា បានសម្រេចសន្និដ្ឋានថា ឌុច មិនបាននិយាយពីរឿងរ៉ាវ

ទាំងអស់ដែលកើតមានឡើងដោយមានដាក់នៅក្នុងសេចក្តីអះអាង ដែលបង្កប់នូវទស្សនៈមួយថា “បុរសម្នាក់នេះ គឺជាសត្វចម្លែក” ។ ផ្ទុយទៅវិញ យើងត្រូវតែយល់ឲ្យបានច្បាស់ថា តើបុរសធម្មតាម្នាក់នេះ ក្លាយជាអ្នកធ្វើទារុណកម្មដ៏សាហាវម្នាក់ដោយរបៀបណា ។ នេះគឺជាអ្វីដែលខ្ញុំចង់ឲ្យសហព្រះរាជអាជ្ញានិយាយ” ។

ហ្វ្រង់ស៊័រ រូ បានចាប់ផ្តើមនិយាយពីមូលន័យសំខាន់នៃការសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់លោក ដែលដកស្រង់ចេញពីសាក្សីសំខាន់ៗ គឺ ដេវីដ ឆេនដ័ល័រ និងពីការនិពន្ធសៀវភៅរបស់លោក ៖ “នេះគឺជាករណីមួយស្តីពីឧក្រិដ្ឋកម្មនៃការគោរពតាមបញ្ជា ។ តើអ្នកក្លាយជាជនល្មើសបានយ៉ាងដូចម្តេច បើអ្នកគ្រាន់តែគោរពតាមបទបញ្ជា?” ហ្វ្រង់ស៊័រ រូ មិនចង់ឲ្យ ឌុច ក្លាយជាអ្នករងកំហុសជំនួសជនដទៃនោះទេ ។ ឌុច មិនគួរចងចាំទុកពីភាពសាហាវព្រៃផ្សៃទាំងអស់ ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងខួរក្បាលរបស់ខ្លួននោះទេ ។ ហ្វ្រង់ស៊័រ រូ បានរិះគន់ពី“សេចក្តីសន្និដ្ឋានមិនសមហេតុផល” និង“ពាក្យសម្តីគួរឲ្យចង់សើច”របស់ព្រះរាជអាជ្ញា ដែលបានចាត់ទុកកូនក្តីរបស់គាត់ថា ជាសត្វចម្លែកដូច្នោះ ។ លោកបានជំទាស់ថា គ្រេក អេតឆេសាន់ ដែលធ្វើការនៅក្នុងការិយាល័យសហព្រះរាជអាជ្ញាគឺជាអ្នកជំនាញដ៏ប៉ិនប្រសប់ម្នាក់ ។

ហ្វ្រង់ស៊័រ រូ បានសួរថា “តើ ឌុច បានក្លាយជា ប៉ុល ពត មែនឬ? បន្ទាប់មក បាននិយាយថា “ខ្ញុំសូមសុំទោសជនរងគ្រោះចំពោះអ្វីដែលខ្ញុំរៀបនឹងនិយាយ ៖ មានមនុស្សច្រើនណាស់បានស្លាប់នៅមន្ទីរស-២១ ប្រមាណ១២,២៨០នាក់ ។ នៅក្នុងប្រទេសកម្ពុជា ប្រជាជន១.៧លាននាក់បានស្លាប់ ។ មន្ទីរស-២១ មានទំនួលខុសត្រូវយ៉ាងហោចណាស់តែមួយភាគរយនៃការស្លាប់ទាំងអស់នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។ យើងក៏បានជឿថា ឌុច គឺជាមនុស្សសាហាវ ដែលធ្វើឲ្យប្រទេសកម្ពុជាពោរពេញដោយឈាម!” ។

ហ្វ្រង់ស៊័រ រ៉ូហ្ស បានបន្តទៀតថា វាមិនចាំបាច់សួរទេថា ឌុច បានទទួលស្គាល់ហេតុការណ៍ទាំងអស់នោះឬយ៉ាងណា ។ ការបាត់បង់ជីវិតនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈធំធេងណាស់ ។ ឌុច បានទទួលស្គាល់ពីទំនួលខុសត្រូវសម្រាប់ជីវិតមនុស្សដែលបានបាត់បង់នៅមន្ទីរស-២១ និងជាពិសេសគឺសម្រាប់ការធ្វើទារុណកម្ម និងការសម្លាប់នៅទីនោះ ។ ឌុច មិនដែលផ្លាស់ប្តូរការទទួលស្គាល់នេះទេ ។ បន្ទាប់មកទៀត ហ្វ្រង់ស៊័រ រូ ក៏បានដកស្រង់ការទទួលស្គាល់ពិរុទ្ធភាពម្តងហើយម្តងទៀត ចំពោះហេតុការណ៍កើត

ឡើងដែលរៀបរាប់ដោយកូនក្ដីរបស់ ដែលបានទទួលស្គាល់ខក្រិដ្ឋកម្មព្រៃផ្សៃកើតមាននៅមន្ទីរស-២១ និងបាននិយាយថា ឌុច មានទំនួលខុសត្រូវចំពោះសកម្មភាពដែលបានប្រព្រឹត្តនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ឌុច បានបញ្ជាក់ពីវិប្បដិសារីរបស់ខ្លួន ដែលថាខ្លួនពិតជាមានវិប្បដិសារីយ៉ាងខ្លាំងដែលវិប្បដិសារីនេះ ឌុច បានវេចស្ពាយជាមួយជគ្រប់ពេលទាំងអស់ក្នុងជីវិតរបស់គេ។ ហ្វ្រង់ស៊័រ រូ បានដកស្រង់ពាក្យសម្ដីដែល ឌុច បាននិយាយកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ដែល ឌុច បានទទួលស្គាល់ថាខ្លួនបានក្បត់មិត្តភក្តិរបស់ខ្លួន ដូច្នេះអ្វីដែលគាត់បានធ្វើគឺពិតជា«ហួសពីភាពកំសាកទៅទៀត»។ ហ្វ្រង់ស៊័រ រូ បានចង្អុលបង្ហាញយ៉ាងច្បាស់ថា ឌុច បានយល់ព្រមសហការក្នុងអំឡុងដំណើរការស៊ើបអង្កេតរបស់រឿងក្ដី និងនៅក្នុងថ្ងៃរំលឹកពីខក្រិដ្ឋកម្មឡើងវិញ។ លោកបានបង្ហាញពីភាពពេញចិត្តថា «ឌុច មិនទាមទារអ្វីទាំងអស់ចេញពីភាពធ្ងន់ធ្ងរនៃខក្រិដ្ឋកម្មទាំងនោះ។ ឌុច គឺពោរពេញទៅដោយវិប្បដិសារី។ ប៉ុន្តែ លោកបាននិយាយទៀតថា សហព្រះរាជអាជ្ញាខ្វះខាតភាពទំនាក់ទំនងជាមួយនឹង ឌុច។ ក្នុងនាមជាមេធាវីរបស់ ឌុច ហ្វ្រង់ស៊័រ រូ និង ការ សាវុត្ថ បានឃើញ ឌុច តែម្នាក់ឯងគត់និយាយដោយស្មោះអស់ពីចិត្តដែលពេលនោះហើយដែល ឌុច ស្រក់ទឹកភ្នែក។ ហ្វ្រង់ស៊័រ រូ បាននិយាយរិះគន់ខ្លាំងទៅកាន់សហព្រះរាជអាជ្ញា សម្រាប់ការមិនទទួលស្គាល់ដែលចារនៅក្នុងការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរជូនចៅក្រម ស្ដីពីការទទួលស្គាល់ពិរុទ្ធភាពរបស់ ឌុច។ «សហព្រះរាជអាជ្ញាមិនដែលបាននិយាយពីការទទួលស្គាល់របស់ខ្លួនម្ដងណាឡើយនៅក្នុងសេចក្ដីសន្និដ្ឋានស្ថាពរនេះ!»។ ចំណែកឯសហចៅក្រមស៊ើបអង្កេត បានទទួលស្គាល់ការយល់ព្រមទទួលស្គាល់ពិរុទ្ធភាពរបស់ ឌុច និងបាននិយាយថា ឌុច បានប្រព្រឹត្តខក្រិដ្ឋកម្មនេះ ដោយសារតែភាពភ័យខ្លាច និងវិប្បសារី។

នៅក្នុងដំណើរការនីតិវិធីកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ ហ្វ្រង់ស៊័រ រូ បាននិយាយទៅកាន់ ឌុច ពីសេចក្ដីអះអាងរបស់សហព្រះរាជអាជ្ញា រ៉ូបឺត ពើទីត ទាក់ទិននឹងអ្វីដែលលោកចង់បានពី ឌុច ដើម្បីមកធ្វើជាការទទួលស្គាល់ពិរុទ្ធភាព។ ហ្វ្រង់ស៊័រ រូ បានសួរ ឌុច ថា «តើអ្នកទទួលស្គាល់ពិរុទ្ធភាពនោះដែលឬទេ?»«ថាអ្នកបានអនុវត្តខក្រិដ្ឋកម្មទាំងអស់នោះ? មែនឬមិនមែន!» ឌុច បានឆ្លើយថា«មែន! ខ្ញុំយល់ព្រមទទួលស្គាល់ពិរុទ្ធភាពនោះទាំងស្រុងតែម្ដង»។

ហ្វ្រង់ស៊័រ រូ បានក្រឡេកទៅកាន់សហព្រះរាជអាជ្ញារួចសួរថា «តើវាអាចនៅមានភាពស្រពិចស្រពិលចំពោះសហព្រះរាជអាជ្ញាដោយរបៀបណាទៅ?» ពីរខែក្រោយ និងក្រោយពីការដាក់សេចក្ដីសន្និដ្ឋាន

សង្ខេបដែលមាន ១៦០ទំព័រជូនទៅកាន់ចៅក្រមនោះ តើសហព្រះរាជអាជ្ញាមិនអាចបញ្ជាក់ពីការទទួលស្គាល់ពិរុទ្ធភាពរបស់ ឌុច នៅថ្ងៃទី១៦ ខែតុលា បានយ៉ាងដូចម្តេចទៅ?

ក្រោយមកទៀត ហ្វ្រង់ស្វ័រ រូ បានលើកឡើងពីសក្ខីកម្មដ៏សំខាន់របស់ ដេវីដ ឆេនដល័រ ។ លោកបានរំលឹកពី ដេវីដ ឆេនដ៍ល័រ ទាក់ទិននឹងការទទួលស្គាល់ពិរុទ្ធភាពរបស់ ឌុច កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ ដែលថា ឌុច មានវិប្បដិសារីនឹងរូបថតទាំងអស់ដែលថតនៅក្នុងមន្ទីរស-២១ដែលខណៈពេលនោះ ឌុច មានមោទនភាពចំពោះការងារដែលខ្លួនកំពុងតែបានធ្វើ ។ ឌុច បាននិយាយថា «ខ្ញុំមានវិប្បដិសារីណាស់» ។ «វាពិតជាគួរឲ្យតក់ស្លុតណាស់ ហើយអ្នកនៅក្នុងរូបថតនោះនឹងមានអារម្មណ៍ថាខ្លួនមានវិប្បដិសារីខណៈពេលដែលរូបខ្លួនមាននៅក្នុងរូបថតបែបនោះ» ។ ហ្វ្រង់ស្វ័រ រូ បាននិយាយថា ឌុច បានទទួលស្គាល់ថាខ្លួនបានបញ្ជា និងធ្វើការគ្រប់គ្រងលើឧក្រិដ្ឋកម្មទាំងនោះ ។ នៅពេលដែលសួរសំណួរបែបនេះ ដេវីដ ឆេនដ៍ល័រ បាននិយាយថា «មែន! អ្វីដែល ឌុច និយាយនឹងមានប្រយោជន៍ដល់ប្រវត្តិសាស្ត្រ ។ ខ្ញុំពិតជារំភើបរីករាយដោយសារតែការ ទទួលស្គាល់ពិរុទ្ធភាពរបស់ ឌុច ។ ឌុចពិតជាបុគ្គលម្នាក់ដែលមានភាពខុសប្លែកពីអ្នកដទៃ ក្នុងចំណោមអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដែលនៅមានជីវិតរស់នៅពីរបបខ្មែរក្រហម» ។

ហ្វ្រង់ស្វ័រ រូ បានចោទប្រកាន់សហព្រះរាជអាជ្ញាពីការច្នៃប្រឌិតប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យសារជាថ្មីម្តងទៀត ។ សហព្រះរាជអាជ្ញា បានពន្យល់រៀបរាប់ថារបបនេះគឺជារបបផ្តាច់ការ ។ លោកបានឆ្លើយតបថា «ប្រសិនបើមន្ទីរស-២១ប្រកាន់នូវគោលជំហរដ៏សំខាន់ ហើយអ្នកគ្រប់គ្រងរបស់មន្ទីរនេះពិតជាមានអំណាចក្នុងការសម្រេចចិត្តដែលថា ឌុច បានណែនាំ ថ្នាក់លើរបស់ខ្លួន និងធ្វើឲ្យថ្នាក់លើមានភាពភ័យខ្លាច នោះរបបនេះមិនមែនជារបបផ្តាច់ការតទៅទៀតទេ ។ វាគឺជាលទ្ធិប្រជាធិបតេយ្យរបស់ប្រជាជនដែលគ្មានថ្នាក់ដឹកនាំ!» ។ ហ្វ្រង់ស្វ័រ រូ បានបន្តទៀតថា «ឌុច គឺជាអ្នកនៅក្រោមបង្គាប់របស់ សុន សេន ។ អ្នកមិនអាចគេចចេញពីការពិតបានទេ ។ ឌុច មិនដែលសប្បាយរីករាយជាមួយនឹងអំណាចគ្រប់គ្រងនៅក្នុងមុខតំណែងរបស់ខ្លួននៅមន្ទីរស-២១ឡើយ ។ គុកនេះត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ។ មន្ទីរស-២១ គឺស្ថិតក្នុងក្រោមការក្របដណ្តប់ និងគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម ។ ហើយ៧៨ភាគរយនៃមនុស្សដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ គឺជាសមាជិករបស់របបនេះ ។ មន្ទីរស-២១ត្រូវបានគ្រប់គ្រងដោយផ្ទាល់

ដោយមជ្ឈមណ្ឌលមជ្ឈិមនៃរបបនេះ” ។

## សក្ខីកម្មរបស់ ក្រេក អេតឆេសាន់

ហ្វ្រង់ស្វ័រ រូ បានអះអាងថា កសិណសាក្សីរបស់ ក្រេក អេតឆេសាន់ បានបង្ហាញពីកំណែថ្មីមួយស្តីពីហេតុការណ៍ដែលបានកើតឡើង ។ បានប្រកាន់គោលជំហរថា ឌុច បានធ្វើឲ្យភាពភ័យខ្លាចចំពោះមេដឹកនាំរបបខ្មែរក្រហមមានលក្ខណៈកាន់តែពុះកញ្ជ្រោលខ្លាំងឡើង ។ ដេវីដ ឆេនដ្ល័រ បានផ្តល់សក្ខីកម្មថា ចម្លើយសារភាពនៅមន្ទីរស-២១ គឺប្រៀបបីដូចជា រនាំងការពារមួយផ្នែករបស់បក្សពីខ្មាំងផ្សេងៗ ។ អេតឆេសាន់ បានទទួលស្គាល់ថា គណៈកម្មាអចិន្ត្រៃយ៍ធ្វើការគ្រប់គ្រងលើសារពត៌មានទំនាក់ទំនងទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះគណៈកម្មាអចិន្ត្រៃយ៍មានលំដាប់ថ្នាក់គ្រប់គ្រងពីលើមកក្រោម ។ ហ្វ្រង់ស្វ័រ រូ បាននិយាយថា គោលបំណងរបស់ ឌុច ត្រូវបានកំណត់ដោយហេតុផលដែលថា នរណាដែលចូលដល់មន្ទីរស-២១ គឺត្រូវតែសម្លាប់ចោល ។ “នេះគឺជាកិច្ចការដ៏សាហាវ ដែល ឌុច ត្រូវបានផ្តល់ឲ្យធ្វើ ។ វាគឺជាការសរសេរប្រវត្តិសាស្ត្រសារជាថ្មីម្តងទៀតដើម្បីអះអាងបញ្ជាក់ថា ឌុច មានឆន្ទះក្នុងការជ្រើសរើសអ្នកត្រូវតែចាប់ខ្លួន ឬអ្នកត្រូវសម្លាប់ចោលដោយឯករាជ្យ” ។ រូ បានជំទាស់នឹងការខិតខំប្រឹងប្រែងរៀបរាប់របស់ អេតឆេសាន់ ដើម្បីចាត់ទុក ឌុច ជាជាប្រភពសំខាន់មួយដែលនាំឲ្យមានការបោសសម្អាតនៅក្នុងមុខតំណែងបុណ្យសក្តិ ។ លោកក៏បាននិយាយសារជាថ្មីម្តងទៀតថា ការស្លាប់ចំនួន១២,៣៨០នេះ គឺមានចំនួនច្រើនណាស់ ប៉ុន្តែការស្លាប់នេះមិនមែនជាការស្លាប់ដែលមានចំនួន ១.៧លាន ដែលមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យត្រូវតែទទួលខុសត្រូវនោះទេ ។

ហ្វ្រង់ស្វ័រ រូ បាននិយាយថាការងាររបស់ ឌុច គឺទាញយកចម្លើយសារភាពនៅមន្ទីរស-២១ ។ ឌុច គឺជាឧបករណ៍នៅក្នុងកណ្តាប់ដៃរបស់បក្ស ហើយ ឌុច បំពេញតួនាទីរបស់ខ្លួនដូចម៉ាស៊ីនដែលគេបញ្ជា ។ យោងតាមសម្តីរបស់ ហ្វ្រង់ស្វ័រ រូ “ឌុច ត្រូវតែជ្រើសរើសសម្លាប់ ឬត្រូវសម្លាប់” ។ ដេវីដ ឆេនដ្ល័រ បានធ្វើកសិណសាក្សីថាប្រសិនបើ ឌុច មិនស្តាប់តាមបញ្ជានោះការសម្លាប់ពិតជាកើតមានឡើងប្រាកដណាស់ ។ បន្ថែមលើនេះ អេតឆេសាន់ ក៏បានផ្តល់កសិណសាក្សីពីការពិតនេះដូចគ្នាផងដែរ ។ សំណួរគឺថា តើហេតុអ្វីបានជា ឌុច មិនរត់គេចខ្លួន? ចម្លើយគឺ ផ្អែកនៅលើមូលហេតុប្រហាក់ប្រហែលរួមគ្នាមួយ ។ សូម្បីតែអ្នកដទៃផ្សេងទៀតមានអំណាចជាង ឌុច ពួកគេនៅតែមិនអាចរត់គេចខ្លួនដោយមានជីវិតផង ។ មេដឹកនាំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទាំងអស់ ដែលបានចូលដល់មន្ទីរស-២១ មិនអាច

រត់គេចខ្លួនបានទេ ។ ហ្វ្រង់ស៊័រ រូ បានសន្និដ្ឋានថា “នេះគឺជាប្រព័ន្ធនៃភាពភ័យខ្លាច និងរោគឆ្កួត” ។ លោកបានបន្តទៀតថា “អ្នកកំពុងតែខឹង ឌុច ដែលបានធ្វើអ្វីៗដែលត្រូវបានទាមទារដោយអ្នករាល់គ្នា!” ។ “តើអ្នកគិតថា វាមានអារម្មណ៍ថាមិន ស្រួលទេឬ ក្នុងការចាត់ទុក ឌុច ថាជាសត្វចម្លែក? សហព្រះរាជអាជ្ញាមិនមានសេចក្ដីក្លាហានក្នុងការទាមទារឲ្យមានការកាត់ទោសជាប់ពន្ធធានាគារអស់មួយជីវិតទេ ពួកគេសម្រេចទាមទារត្រឹមតែការកាត់ទោសឲ្យជាប់ពន្ធនាគារ៤០ឆ្នាំប៉ុណ្ណោះ ។ តើនេះមិនមែនជាដំណោះស្រាយដែលស្រួលពេកឬទេ?”

## សេចក្ដីបន្ទាប់បញ្ញារបស់លោកប្រធានាធិបតេយ្យ អូបាម៉ា

ហ្វ្រង់ស៊័រ រូ បានណែនាំថា កិច្ចការពិតប្រាកដរបស់សហព្រះរាជអាជ្ញា គួរតែធ្វើការស្វែងរកពីការពិតនៃបាតុភូតដែលបុរសធម្មតាម្នាក់នេះ បានក្លាយទៅជាឃាតករសម្លាប់មនុស្ស ។ បាននិយាយថា យើងផាកមកមើលការសិក្សាស្រាវជ្រាវដ៏សំខាន់របស់ ដេវីដ ឆេនដ៍ល័រ គឺ ៖ ឧក្រិដ្ឋកម្មនៃការគោរពតាមបញ្ញា ។ ហ្វ្រង់ស៊័រ រូ បាននិយាយថា លោកបានធ្វើការការពារ ក្ដីដល់ការមិនគោរពតាមច្បាប់របស់ប្រជាជននៅក្នុងបន្ទប់សវនាការអស់រយៈពេល៣៥ឆ្នាំ ក្នុងគោលបំណងកែប្រែច្បាប់ដោយស្មារតីដូចគ្នានឹង មហាត្មៈ ហ្គាន់ឌី ដែលបានអនុវត្តនៅក្នុងប្រទេសឥណ្ឌា ។ ហ្វ្រង់ស៊័រ រូ ក៏បានធ្វើការកត់សម្គាល់លើពាក្យសម្ដីរបស់ បារ៉ាក់ អូបាម៉ា ដែលបានថ្លែងកាលពីប៉ុន្មានខែកន្លងទៅនេះថា មនុស្សទាំងឡាយដែលបំពេញកាតព្វកិច្ចដោយមានជំនឿជឿជាក់ល្អតាមដំបូន្មានរបស់ស្ថាប័នយុត្តិធម៌ ក្នុងអំឡុងរដ្ឋាបាលគ្រប់គ្រងរបស់ ប៊ូស នៅក្នុងការសួរចម្លើយលើជនសង្ស័យពីអំពើភេរវកម្មដែលរួមមានសកម្មភាពធ្វើទារុណ្ណកម្មនឹងមិនត្រូវបានកាត់ទោសប្រហារជីវិតទេ ។ តើសេចក្ដីបន្ទាប់បញ្ញានេះអាចនឹងមានលក្ខណៈផ្ទុយគ្នានឹងអ្វីដែល ឌុច បានប្រឈមមុខនៅក្នុងមន្ទីរស-២១ ដូចជាការធ្វើតាមបញ្ញាលើកិច្ចការសួរចម្លើយអ្នកទោសបានដោយរបៀបណាទៅ? ហេតុអ្វីបានជាបុគ្គលិករបស់សហរដ្ឋអាមេរិកមិនគោរពតាមបញ្ញា? “ប្រសិនបើយើងមិនរៀនពីរបៀបបដិសេធមិនគោរពតាមបញ្ញានៅក្នុងលទ្ធិប្រជាធិបតេយ្យទេ តើយើងអាចធ្វើវាបានដោយរបៀបណានៅក្នុងរបបផ្ដាច់ការ?” ហ្វ្រង់ស៊័រ រូ បាននិយាយថា យើងទាំងអស់គ្នាធ្វើការសហការគ្នា ជាពិភពលោកតែមួយដែលយើងត្រូវតែសួរមេដឹកនាំយើងថា តើយើងត្រូវធ្វើអ្វីខ្លះ ។ តើយើងទាំងអស់គ្នាមានជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មនៃការគោរពតាមបញ្ញាដែរឬទេ? “ក្រោយពី៣៥ឆ្នាំនៃការការពារក្ដីទាក់ទិននឹងការមិនគោរពតាមបញ្ញានៅទីនេះ ខ្ញុំបានឈរការពារក្ដីឲ្យមនុស្សម្នាក់ ដែលគោរពតាមបញ្ញារបស់ខ្លួនដោយក្លែងក្លាយ” ។

# ការប្រព្រឹត្តខុសព្រហ្មទណ្ឌកម្មរួម

បន្ទាប់មកទៀត ហ្វ្រង់ស៊័រ រ៉ូ បានលើកឡើងមកវិញពីគោលបំណងជាបន្តបន្ទាប់របស់សហព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ឌុច ថាអាចមានជាប់ពាក់ព័ន្ធនឹងទ្រឹស្តីការប្រព្រឹត្តខុសព្រហ្មទណ្ឌកម្មរួម ។ លោកបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមិនអាចកំណត់ថា ឌុច បានប្រព្រឹត្តខុសព្រហ្មទណ្ឌកម្មនៅក្នុងការប្រព្រឹត្តខុសព្រហ្មទណ្ឌកម្មរួមជាមួយនឹងជនដែលអង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់សិទ្ធិឲ្យបង្ហាញខ្លួនការពារខ្លួនគេពីការចោទប្រកាន់នោះឡើយ ។ សហព្រះរាជអាជ្ញាគួរតែទាមទារឲ្យមានកិច្ចប្រជុំបញ្ចប់ដើម្បីឲ្យជនទាំងអស់នេះអាចធ្វើកសិណសាក្សីការពារខ្លួនគេពីទ្រឹស្តីប្រព្រឹត្តខុសព្រហ្មទណ្ឌកម្មរួម ។

បន្ថែមលើនេះ ហ្វ្រង់ស៊័រ រ៉ូ បញ្ជាក់ថា ឌុច មិនអាចត្រូវបានកាត់ទោសសម្រាប់ការធ្វើទារុណកម្មខ្លួនឯង ដូចដែរសហព្រះរាជអាជ្ញាបានអះអាងក្នុងសប្តាហ៍នេះទេ ។ អង្គបុរេជំនុំជម្រះបានដកទាស់នឹងបទចោទប្រកាន់នោះ ។ បន្ទាប់មកទៀត ហ្វ្រង់ស៊័រ រ៉ូ បានចាប់ផ្តើមនិយាយពីការរិះគន់ដ៏វែងមួយទៅលើវិធានទី៨៧ ដែលតម្រូវឲ្យចៅក្រម«ត្រូវតែជឿលើពិរុទ្ធភាពរបស់ជនត្រូវចោទ ដែលមានលក្ខណៈហួសពីមន្ទិលសង្ស័យដែលសមហេតុផល» ។ លោកបានអះអាងថា មានបញ្ហាបានកើតឡើងនៅក្នុងការបកប្រែវិធានពីភាសាអង់គ្លេសច្បាប់ដើមមកភាសាបារាំង ។ លោកសង្ឃឹមថា ចៅក្រមនឹងត្រូវបាននាំផ្លូវដោយ«ការផ្តន្ទាទោសតាមការពេញចិត្តរបស់ចៅក្រម» នៅពេលដែលសម្រេចពីពិរុទ្ធភាពរបស់ ឌុច ។

ហ្វ្រង់ស៊័រ រ៉ូ បានព្យាយាមអធិប្បាយ ឌុច ជាមនុស្សសប្បុរសធម៌ជាបុរស«រុះរាយ»និង«រុំទម»ម្នាក់ ។ លោកបាននិយាយដោយដកស្រង់ចេញពីទំព័រ ២៥៦នៃសៀវភៅរបស់ នីក ដងឡុប ដែលនិយាយថា ឌុច ដែលអស់រយៈពេលយ៉ាងយូរក្រោយពីរបប ប៉ុល ពត បានកន្លងផុតទៅ ឌុច បានជួយទប់ស្កាត់ការរីករាយដាលនៃជម្ងឺគ្រុនពោះវៀន នៅក្នុងជំរុំមនុស្សធម៌ជាកន្លែងដែល ឌុច បានធ្វើការជួយសង្គ្រោះជីវិតមនុស្សរាប់មិនអស់ ។

ហ្វ្រង់ស៊័រ រ៉ូ បានលើកឡើងពីទស្សនៈដែលថា ឌុច បានទទួលរងនូវជម្ងឺតានតឹងផ្នែកសតិអារម្មណ៍ ដែលអាចធ្វើឲ្យអ្នកមានជម្ងឺនេះគេចចេញពីការពិត និងមានអារម្មណ៍ថាមិនដឹងស្មារតី ។ លោកនៅតែជឿ

ជាក់ថា មានរឿងមួយចំនួនទៀតដែល ឌុច នៅមិនទាន់ប្រាប់ ដូច្នេះជម្ងឺតានតឹងផ្នែកសតិអារម្មណ៍នេះហើយជាមូលហេតុ ។

## ការកាត់ទោសរបស់ ឌុច

ទាក់ទិននឹងការកាត់ទោស ឌុច, ហ្វ្រង់ស្វ័រ រូ បានកត់សម្គាល់ឃើញថា នៅក្នុងតុលាការឧក្រិដ្ឋកម្មផ្សេងទៀត បានចាត់ទុកការគោរពតាមបញ្ជារបស់ថ្នាក់លើជាកត្តាសម្រាលទោស ។ បាននិយាយទៀតថា ឌុច ជាប់នៅក្នុងច្រវ៉ាក់ចេញបញ្ជានិងជាទាសករ ហើយក៏ជាឈ្លើយសឹករបស់របបនេះ ។ លោកក៏បានបង្ហាញប្រាប់ថា ឌុច នឹងបន្តសហការនៅក្នុងរឿងក្តីលេខ០០២ ។ តាមពិត ឌុច និងមេធាវីរបស់ខ្លួនបានជួបជាមួយនឹងសហចៅក្រមស៊ើបអង្កេតកាលពីពីរសប្តាហ៍មុន ហើយពួកគេនឹងជួបគ្នាម្តងទៀតនៅសប្តាហ៍ក្រោយ ។ ហ្វ្រង់ស្វ័រ រូ មានភាពសោកស្តាយដែលមិនបានលើកឡើងពីការសហការជាបន្តបន្ទាប់របស់កូនក្តីគាត់តាំងពីដំបូងនៅក្នុងតុលាការកាត់ទោសនេះ ។

ហ្វ្រង់ស្វ័រ រូ បានគិតថា ឌុច ត្រូវបានកាត់ទោសឲ្យទទួលភារកិច្ចពន្យល់ក្មេងជំនាន់ក្រោយ ដែលមកធ្វើទស្សនកិច្ចនៅវាលពិឃាតជើងឯក ពីអ្វីដែលពួកគេមិនគួរធ្វើនាពេលអនាគត ។

## ការការពារក្តីរបស់ អាល់ប៊ឺត ស្ពៀរ

តាំងពីម្សិលមិញ ហ្វ្រង់ស្វ័រ រូ បានទទួលស្គាល់ថា គ្មានការយល់ព្រមទទួលស្គាល់ពិរុទ្ធភាពដោយកូនក្តីរបស់លោកតទៅទៀតឡើយ ។ "ឥឡូវនេះ យើងកំពុងតែស្ថិតនៅក្នុងការការពារក្តីរបស់ អាល់ប៊ឺត ស្ពៀរ ហើយ ។ នៅឯនូរីមប៊ឺក ស្ពៀរ មិនបានយល់ព្រមទទួលស្គាល់ពិរុទ្ធភាពឡើយ ប៉ុន្តែលោកបានទទួលស្គាល់ពីទំនួលខុសត្រូវរបស់លោក ។ ព្រះរាជអាជ្ញា Jackson បានផ្តល់តម្លៃដល់ការទទួលស្គាល់ទំនួលខុសត្រូវរបស់ ស្ពៀរ ដោយនិយាយថា ស្ពៀរ គឺជាជនត្រូវចោទដែលល្អជាងគេបំផុតនៅក្នុងចំណោមជនត្រូវចោទអាក្រក់ទាំងអស់នៅក្នុងប្រទេសនូរីមប៊ឺក ។ ស្ពៀរ ទទួលបានការកាត់ទោសជាប់ពន្ធនាគារ២០ឆ្នាំ ចំណែក អុប្រ៊ែណ្ឌូវិច ទទួលបានការកាត់ទោសជាប់ពន្ធនាគារ១៧ឆ្នាំ ។ ហ្វ្រង់ស្វ័រ រូ បានសួរថា "តើ ឌុច អាចនៅមានប្រយោជន៍សម្រាប់មនុស្សជាតិដែរឬទេ?" លោកបានអះអាងថា ឌុច បានធ្វើជាជនរត់គេចខ្លួនអស់រយៈពេល២០ឆ្នាំ និងបានជាប់ឃុំឃាំងអស់រយៈពេល១០ឆ្នាំ ។

ដូច្នេះសម្រាប់រយៈពេល៣០ឆ្នាំកន្លងមក ឌុច មិនមែនជាមនុស្សដែលមានសេរីភាពនោះទេដែលជាចំណុចដែលសហព្រះរាជអាជ្ញានឹងជំទាស់នៅថ្ងៃសុក្រនេះ ។ ហ្វ្រង់ស្វ័រ រូ បាននិយាយថា ឌុច បានលាងជម្រះនូវអំពើអាក្រក់ដែលខ្លួនបានធ្វើ ។ លោកបានស្នើសុំថា "បញ្ជូន ឌុច ត្រលប់ទៅផ្ទះវិញទៅ!" នៅក្នុងភ្នែករបស់មនុស្ស ឌុច នឹងមិនត្រូវបានអត់ឱនទោសនោះទេ ។ "ប៉ុន្តែតើយើងអាចក្រលេកមើលភ្នែករបស់ ឌុច និងចាត់ទុក ឌុច ជាមនុស្សធម្មតាបានដែរឬទេ? តើអ្នកនឹងនាំយក ឌុច ត្រឡប់ទៅកាន់ក្រុមមនុស្សជាតិវិញដែរឬទេ? ឌុច បានស្លាប់ហើយ ។ សព្វថ្ងៃនេះ ឈ្មោះរបស់គាត់គឺកាំង ហ្កេកអ៊ាវ ។ គាត់មិនមែនជា ឌុច របស់បដិវត្តន៍តទៅទៀតទេ" ។

ក្រោយពីបានបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលដ៏អស្ចារ្យមក ហ្វ្រង់ស្វ័រ រូ បានអង្គុយចុះ ។ បន្ទាប់មកលំដាប់ថ្នាក់នៃការជំទាស់នៅក្នុងការបញ្ចប់ការសួរដេញ ដោលបានចាប់ផ្តើមដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋាន ។

## ដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ

ការីម ខាន បានចាប់ផ្តើមធ្វើសេចក្តីជំទាស់របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្នុងតួនាទីជាមេធាវីរបស់ក្រុមមួយ ។ លោកបានទទួលស្គាល់ថា សេចក្តីថ្លែងការណ៍ដ៏ច្បាស់របស់ ហ្វ្រង់ស្វ័រ រូ ពិតជាពោរពេញដោយបទពិសោធន៍ច្រើន ភាពទាក់ទាញនិងប្រកបដោយសមត្ថភាព ។ ប៉ុន្តែ បានចាប់ផ្តើមធ្វើការជំទាស់តបទៅវិញភ្លាមៗ ។ លោកបានចោទប្រកាន់ ឌុច ថា ព្យាយាមជិះសេះពីរក្នុងពេលតែមួយ ។ នៅក្នុងអំឡុងពេលចុងក្រោយនេះអ៊ីៗបានផ្លាស់ប្តូរកាលពីថ្ងៃពុធ ។ អស់រយៈពេលជាច្រើនខែកន្លងមកនេះ ឌុច បានបង្ហាញពីការទទួលស្គាល់ពិរុទ្ធភាពនៅក្នុងព័ត៌មានដែលមានជាប់ពាក់ព័ន្ធទាំងអស់ ប៉ុន្តែឥឡូវនេះ ឌុច បែរជាសុំឲ្យរួចទោស និងដោះលែងឲ្យមានសេរីភាព ។ ការីម ខាន បាននិយាយថា នេះគឺជារឿងអយុត្តិធម៌មួយសម្រាប់ប្រជាជនខ្មែរទាំងអស់ ។

គ្មានបទប្បញ្ញត្តិណាមួយដែលមានលក្ខណៈប្រហាក់ប្រហែលនឹងវិធានទី៧១ របស់វិធានផ្ទៃក្នុងសម្រាប់ការមិនយល់ស្របគ្នារវាងមេធាវីការពារក្តីនោះទេ ។ ការមិនយល់ស្របគ្នាប្រភេទនេះ គួរតែត្រូវបាន

ដោះស្រាយដោយសមហេតុផលដោយកូនក្តីដែលអាចនឹងផ្តល់ជាសេចក្តីបន្ទាប់បញ្ហាមេធាវី ឲ្យធ្វើអ្វីដែលកូនក្តីនោះចង់បាន ។ ការីម ខាន បាននិយាយថា នៅក្នុងភាពពាក់ព័ន្ធគ្នានេះដែរ អ្វីដែលបានកើតឡើងនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់ ការ សាវុត្ថ កាលពីថ្ងៃពុធ គឺជាការរំលោភបំពានមួយនៅក្នុងដំណើរការនីតិវិធី ។

ការីម ខាន បានងាកមកនិយាយពីការចោទប្រកាន់របស់ ហ្វ្រង់ស័រ រូ ដែលថា សហព្រះរាជអាជ្ញាបានបាត់បង់នូវឱកាសក្នុងការធ្វើឲ្យការបញ្ចប់ការសួរដេញដោលរបស់ខ្លួនមានលក្ខណៈសំខាន់ ។ ការីម ខាន បាននិយាយថា “តាមទស្សនៈរបស់ខ្ញុំ ឌុច បានបាត់បង់នូវឱកាសដ៏សំខាន់ក្នុងការនិយាយឲ្យច្បាស់ស្របពេលនិងស្មោះត្រង់នៅក្នុងអង្គសវនាការ ។ ឌុច គឺជាមេដឹកនាំស្របច្បាប់របស់មន្ទីរស-២១ ប៉ុន្តែជាក់ស្តែង ឌុច បានស្ម័គ្រចិត្តចូលរួមជាមួយនឹងការផ្សងព្រេងនេះ ។ ឌុច បានឈប់ធ្វើការជាមួយនឹងសហព្រះរាជអាជ្ញាជាជាងផ្សារភ្ជាប់ទំនាក់ទំនងជាមួយអ្នកទាំងនោះ” ។ សកម្មភាពនៃការភ្ញាក់ខ្លួន ការសម្តែងនូវភាពស្មោះត្រង់ និងការទទួលយកការពិតដោយស្មោះត្រង់ គឺពិតជាមានតម្លៃ និងគឺជាអ្វីដែល ឌុច អាចផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណី ។ ការីម ខាន បាននិយាយថា ទឹកភ្នែកតែមួយមុខមិនអាចបញ្ឈាក់បានទេ ។

ការីម ខាន បានបន្តទៀតថា ការលើកឡើងពីជម្ងឺតានតឹងផ្នែកសតិអារម្មណ៍របស់ ហ្វ្រង់ស័រ រូ ពិតជាមិនមានជាប់ពាក់ព័ន្ធទាំងស្រុង និងបាននិយាយថា នេះគឺជាអង្គសវនាការច្បាប់មិនមែនជាកន្លែងដែលអ្នកអាចនាំយកនូវការស្មាន ដោយគ្មានការគាំទ្រចូលមកក្នុងបន្ទប់សវនាការនៅពេលចុងក្រោយនេះទេ ។ លោកក៏បានអះអាងថា “វាមានឱកាសដល់ទៅ១២,៣៨០ឱកាស ដែល ឌុច អាចធ្វើកិច្ចការមួយដែលត្រឹមត្រូវ ។ ប៉ុន្តែ ឌុច បែរជាពេញចិត្តនឹងភាពខ្មៅងងឹងទាំងអស់នោះទៅវិញ” ។ លោកបានបន្តទៀតថា មេធាវីការពារក្តីបានចាត់ទុកខុសថាបញ្ហានេះគឺជាបញ្ហាពង្រីកអាជ្ញាយុកាលលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ តាមអ្វីដែល ការ សាវុត្ថ បានអះអាងកាលពីថ្ងៃពុធ ។ តាមការអះអាងរបស់ ការ សាវុត្ថ សម្រាប់ការខ្វះខាតនូវយុត្តាធិការផ្ទាល់ខ្លួនតាមវិធានទី៨៩ នៃការបដិសេធតាំងពីដំបូងស្តីពីលក្ខណៈបញ្ហានោះថា គួរតែត្រូវបានដាក់ជូនក្នុងអំឡុងពេល៣០ថ្ងៃនៃដីកាដំណោះស្រាយ ។ យ៉ាងណាមិញ មានច្បាប់ករណីជាច្រើនដើម្បីបញ្ឈប់សេចក្តីជំទាស់នេះ ។ សម្រាប់ទ្រឹស្តីនៃការប្រព្រឹត្តឧក្រិដ្ឋកម្មរួម ការីម ខាន បានកត់សម្គាល់ពីសាលក្រមរបស់សេរ៉ុមបា កាលពីថ្ងៃទី១២ ខែមិនា ឆ្នាំ២០០៨ ដោយតុលាការកាត់ទោសអន្តរជាតិសម្រាប់រ៉្វាន់ដា ។ ចៅក្រមនៅក្នុងតុលាការនោះ បានសម្រេចថា

វាមិនមានភាពជាប់ពាក់ព័ន្ធគ្នាដែលថាជន ត្រូវចោទមិនបានគ្រប់គ្រងម៉ាស៊ីនឈូសបន្ទ្រាបដីនោះឲ្យក្លាយជាម៉ាស៊ីនសម្លាប់មនុស្សដោយផ្ទាល់នោះទេ ។ ជនត្រូវចោទបានអនុវត្តឥទ្ធិពលលើអ្នកប្រើប្រាស់ម៉ាស៊ីននោះ ដូច្នេះវាមានលក្ខណៈគ្រប់គ្រាន់ដើម្បីសិក្សាពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួមនៅក្នុងករណីនោះ ។

ការីម ខាន បានសន្និដ្ឋានបញ្ចប់ដោយនិយាយថា «យើងមិនដឹងពីអ្វីដែលនឹងត្រូវបាននិយាយដោយមេធាវីការពារក្តីតទៅទៀតទេ ។ ហ្វ្រង់ស៊័រ រូ អះអាងថា ឌុច មិនយល់ព្រមទទួលស្គាល់ពិរុទ្ធភាព ប៉ុន្តែមានការភ្ញាក់ខ្លួន ។ ចំណែកឯ ការ សាវុត្ថ ចង់ឲ្យ ឌុច ត្រូវបានដោះលែងឲ្យមានសេរីភាព» ។

## ដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ

ស៊ីលយិ ស្តូតហ្សីនស្គី បានក្រោកឈរតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។ ភ្លាមៗលោកស្រីបានជំទាស់ថា ការយល់ព្រមទទួលស្គាល់ថាគ្មានពិរុទ្ធភាពរបស់ ការ សាវុត្ថ កាលពីថ្ងៃពុធ គឺប្រៀបដូចជា«ការទះកម្ផៀងរបស់ដើមបណ្តឹងរដ្ឋប្បវេណី» ។ ដើមបណ្តឹងរដ្ឋប្បវេណីមានភាពភ្ញាក់ផ្អើលចំពោះសំណូមពរសុំឲ្យមានសាលក្រមសម្រេចឲ្យរួចទោសពីបទចោទប្រកាន់ និងការដោះលែង ។ លោកស្រីបាននិយាយថា ឌុច បានលេងល្បែងដ៏ល្អនេះនឹងកំពុងតែលេងបន្តទៀត ។ ប៉ុន្តែ ពេលវេលាបកស្បែកចៀមបានមកដល់ហើយ ។ បន្ទាប់មកទៀត លោកស្រីបានផ្តល់ព័ត៌មានបន្ថែមលើចំនុចជាច្រើនដែលលើកឡើងដោយ ការីម ខាន កាលពីប៉ុន្មាននាទីកន្លងទៅនោះ ។ លោកស្រីបានបញ្ជាក់ថា ការជំទាស់លើយុត្តាធិការផ្ទាល់ខ្លួនគួរតែត្រូវបានស្នើសុំឲ្យមានការពិភាក្សាមុននេះ ហើយបញ្ហានេះមិនអាចទទួលយកបានទេនៅក្នុងដំណាក់កាលនេះ ។ ការ សាវុត្ថ មិនបានយល់ច្បាស់ពីមាត្រាទី៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាដែលគ្មានបញ្ជាក់ពីទស្សនៈនៃវិសមភាពសម្រាប់ភាពអយុត្តិធម៌នោះទេ ។ លោកស្រីបាននិយាយថា មិនមានសិទ្ធិបែបនេះកើតឡើងទេ ។ ភាពស្របច្បាប់នៃសេចក្តីសម្រេចមួយ មិនអាចទទួលស្គាល់សម្រាប់កំហុសដើម្បីកាត់ទោសជនដទៃផ្សេងទៀតឡើយ ។

ស្តូនហ្សីនស្គី បានអះអាងថា សេចក្តីអះអាងរបស់ ការ សាវុត្ថ ទាក់ទិននឹងការការពារក្តីស្តីពីបញ្ជារបស់ថ្នាក់លើបានប្រមាថដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ហើយចំពោះអ្វីដែលបានលើកឡើងនោះ ពិតជាមិនបានធ្វើឲ្យពិរុទ្ធភាពរបស់ ឌុច មានភាពធូរស្រាលនោះទេ ។ វាគ្រាន់តែអាចចាត់ទុកថា ជាកត្តាសម្រាលទោសសម្រាប់ការកាត់ទោសតែប៉ុណ្ណោះ ។

លោកស្រីក៏បានបន្ថែមថា ភាពសមហេតុផលថ្មីរបស់ក្រុមមេធាវីការពារក្តី ហាក់បីដូចជាចង់មានន័យថា ឌុច បានគេចផុតពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដូច្នេះ មានតែ ប៉ុល ពត ទេដែលមានទំនួលខុសត្រូវតាមផ្លូវច្បាប់ ។ យុត្តិសាស្ត្រមេធាវីការពារក្តីរបស់ ឌុច មិនបានផ្តល់អត្ថប្រយោជន៍ អ្វីដល់ដំណើរការផ្សះផ្សាជាតិទេ ។ ឥឡូវនេះ ដើមបណ្តឹងរដ្ឋប្បវេណីកាន់តែមិនមានភាពគួរឲ្យអាណិតអាសូរឡើយ ។ ជាក់ស្តែង យុត្តិសាស្ត្ររបស់មេធាវីការពារក្តី ពិតជាមានលក្ខណៈផ្ទុយពីការសម្តែងនូវវិប្បដិសារីដ៏ស្មោះត្រង់របស់ជនត្រូវជាប់ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍មុន ។ លោកស្រីបានបន្ថែមទៀតថា បំណងរបស់ ឌុច ដែលចង់វិលត្រឡប់ចូលក្នុងសង្គមកម្ពុជាវិញនោះត្រូវតែជិតទាស់ ។

## ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី

ម៉ាទីន ហ្សាកកាំង បានក្រោកឈរតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។ លោកស្រីបាននិយាយថា ដើមបណ្តឹងរដ្ឋប្បវេណី មិនទាន់បានឮពាក្យសម្តីដែលផ្តល់ជាអត្ថប្រយោជន៍ដ៏ជ្រាលជ្រៅពី ឌុច ទេ ។ «អ្នកខូះនូវឆន្ទៈក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម អ្នកក៏ខ្វះនូវឆន្ទៈនៅក្នុងតុលាការនេះដែរ! ។ អ្នកមិនបានសុំឲ្យមានការអត់ឱនទោសដោយពិតប្រាកដនោះទេ ។ អ្នកបានបាត់បង់ឱកាសសម្រាប់ពេលវេលាប្រវត្តិសាស្ត្រក្នុងប្រទេសរបស់អ្នក ។ អ្នកមិនបានយល់ពីបំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ។ អ្នកមិនបានធ្វើឲ្យខ្លួនរបស់អ្នកឃ្លាតឆ្ងាយពីសេចក្តីសុខក្សេមក្សាន្តនៃឃាតកម្មរបស់របបនេះឡើយ ។ អ្នកបានសុំសេចក្តីអាណិតអាសូរពីជនរងគ្រោះដែលអ្នកទាំងអស់នោះមិនដែលទទួលបានពីអ្នកឡើយ» ។ នៅក្នុងសេចក្តីរៀបរាប់ទាំងស្រុងរបស់ ម៉ាទីន ហ្សាកកាំង, ឌុច បានសម្លឹងមើលមុលោកស្រីរហូត ។ (តាមធម្មតា ឌុច មិនបានងាកមើលភាគីប្រឆាំងឡើយ) ។

បន្ទាប់មក ហ្វីលីព កានណុន បាននិយាយបន្តដោយចាប់ផ្តើមសរសើរ ហ្វ្រង់ស្វ័រ រ៉ូ សម្រាប់ការងារដែលលោកបានបម្រើជូនច្បាប់អស់រយៈពេលច្រើនសតវត្សន៍ ។ លោកបាននិយាយថា «តើយើងអាចសរសើរចំពោះការយល់ព្រមទទួលស្គាល់ពិរុទ្ធភាពបានប៉ុណ្ណា? យើងប្រហែលជាអាចឈានទៅដល់ការកាត់ទោសដែលមានលក្ខណៈយុត្តិធម៌ នេះគឺជាស្ពានចម្លងមួយ ។ យើងរំពឹងទុកនូវពាក្យសម្តីដែលស្តែងពីភាពស្មោះត្រង់ មិនមែនភាពស្រណុកស្រួលនោះទេ ។ យើងបានស្តាប់ឮពី ឌុច នូវព្រឹត្តិការណ៍គួរលេខសំណុំរឿង និងឯកសារជាច្រើន ។ ឌុច បានធ្វើការប្រតិបត្តិការនៅក្នុងរបៀបគ្រប់គ្រងចាត់ការ

រដ្ឋដ៏ចម្លែកក្នុងអំឡុងពេលដែលហេតុផល និងការយល់ដឹងត្រូវបានអវត្តមានទាំងស្រុង ។ ហើយឥឡូវនេះ មេធាវីការពារក្តីស្នើសុំឲ្យមានសាលក្រមសម្រេចឲ្យរួចទោសពីបទចោទប្រកាន់សម្រាប់ ឌុច ។ នេះគឺជាភាពមិនទទួលខុសត្រូវឡើយ!»

ហ៊ីលីព កានណុន បានអះអាងថា ការបញ្ជាត្រូវតែមិនគោរពតាមប្រសិនបើបញ្ជានេះ ប្រកបដោយភាពសាហាវឃោរឃៅ ម្យ៉ាងវិញទៀត ឌុច មានសេរីភាពក្នុងការមិនគោរពតាមបញ្ជា ប៉ុន្តែ ឌុច ជិទាស់មិនធ្វើដូច្នោះ ។ ឌុច មិនបាននិយាយពីការពិភាក្សានៃសំណាងថ្លៃខូចខាតម្តងណាឡើយ ។ តើដើមបណ្តឹងរដ្ឋប្បវេណីអាចស្តាប់ពុស្ថិតិតែមួយភាគរយនៃការស្លាប់នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលដែលបានកើតឡើងនៅមន្ទីរស-២១ បានយ៉ាងដូចម្តេច? «តើអ្នកអាចនិយាយដូច្នោះ ទៅកាន់អ្នកទាំងនោះដោយរបៀបណា?» ទាំងនេះ គឺជាស្ថិតិដ៏ធ្ងន់ធ្ងរដែលដាក់បន្ទុកនៅក្នុងក្រអៅបេះដូងរបស់ជនរស់រានមានជីវិត» ។

## ដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន

ហុង គឹមសួន បានក្រោកនិយាយតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ។ លោកបាននិយាយទាំងមានអារម្មណ៍រំជើបរំជួលនិងបានឈប់និយាយពីរលើដើម្បីរៀបចំខ្លួនសារជាថ្មីម្តងទៀត ។ បាននិយាយថា លោកគឺជាជនរងគ្រោះម្នាក់ ហើយវាពិបាកក្នុងការរៀបរាប់ពីខ្លួនគាត់ណាស់ ។ លោកបន្តទៀតថា «ខ្ញុំសូមសុំទោសចំពោះការមិនគ្រប់គ្រងអារម្មណ៍របស់ខ្ញុំឲ្យបានល្អ» ។
ហុង គឹមសួន បានចោទ ការ សារុត្ត ពីការនិយាយផ្ទុយពីអ្វីដែល ឌុច បាននិយាយរួចហើយនៅក្នុងតុលាការទាក់ទិននឹងទំនួលខុសត្រូវរបស់ ឌុច ។ ដូច្នេះ ការធ្វើបែបនេះ បានបង្កឲ្យមានភាពឈឺចាប់ និងទុក្ខវេទនាកាន់តែខ្លាំងឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណី ។ តើវាគួរឲ្យជឿដែរឬទេក្នុងការអះអាងថា ឌុច គឺមិនមែនជាជនដែលមានទំនួលខុសត្រូវខ្ពស់ ឬមិនមែនជាមេដឹកនាំជាន់ខ្ពស់? ឌុច គឺជាជនដែលមានទំនួលខុសត្រូវខ្ពស់ជាងគេនៅខណៈពេលដែល ឌុច គ្រប់គ្រងការសម្លាប់មនុស្សដែលមានចំនួនលើសពី ១២,០០០នាក់ ។ បទពិសោធន៍របស់ ឌុច នៅមន្ទីរម-១៣ បានធ្វើរបបខ្មែរក្រហមជឿទុកចិត្ត និងតំលើងតំណែងឲ្យធ្វើជាអ្នកគ្រប់គ្រងមន្ទីរស-២១ ដើម្បីទាញយកចម្លើយសារភាព ។ ហុង គឹមសួន បាននិយាយថា នេះគឺជាការកុហក់ ខណៈពេលដែល ឌុច បានអះអាងថាខ្លួនមិនអាចរត់គេចខ្លួនបានទេ

និងក្លាយជាមនុស្សតូចតាចនៅក្នុងរបបនេះតែប៉ុណ្ណោះ ។ ឌុច បានបន្ថែមព័ត៌មានផ្ទាល់ខ្លួនជាច្រើននៅក្នុងឯកសារនៃការសម្លាប់ទាំងអស់នោះអស់រយៈពេលរាប់ឆ្នាំ ។

ហ៊ុន សែន គឹមសួន បានសុំឲ្យមានការកាត់ទោសកម្រិតធ្ងន់ ។ បានស្នើសុំឲ្យមានការចាក់ផ្សាយការសុំទោសរបស់ ឌុច តាមវិទ្យុ ។ ក្រោយមក លោកក៏បានបញ្ចប់ដោយស្នើសុំឲ្យមានការសាងសង់រូបចម្លាក់របស់ ឌុច ក្នុងលក្ខណៈស្លៀកឯកសណ្ឋាននៅមន្ទីរស-២១ ដើម្បីរំឭកដល់អ្នករាល់គ្នាថា ឌុច គឺជាឧក្រិដ្ឋជន ។ ប្រជាជនកម្ពុជាដែលមានវត្តមាននៅក្នុងសាលទស្សនាសាធារណៈបាននាំគ្នាភ្ញាក់ផ្អើលនឹងការស្នើសុំនេះ អ្នកខ្លះនាំគ្នាសើចចំពោះគំនិតនេះ ឬឯអ្នកផ្សេងទៀតបង្ហាញពីចំណាប់អារម្មណ៍នៃភាពព្រឺខ្លាចរបស់គេ ។